ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំយុវជន និងកីឡា

លេខ ៣០៥៤ អយក.សស.

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០០០

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## ជំរាបមក

## លោក លោកស្រី ប្រធានគ្រប់អង្គភាព និង គ្រឹះស្ថានសិក្សាក្រោមឱវាទ

## លោក លោកស្រី ប្រធានមន្ទីរអប់រំយុវជន និងកីឡា គ្រប់ខេត្តក្រុង

**កម្មវត្ថុ:** អនុវត្តការហាមឃាត់ជក់បារីនៅតាមកន្លែងធ្វើការ គ្រឹះស្ថានសិក្សា សាលប្រជុំនានា រោងមហោស្រព ។

**យោង:** សេចក្តីអំពាវនាវរបស់ ក្រសួងអប់រំ យុវជន និងកីឡា លេខ ៤៥៥ អយក.ម ចុះថ្ងៃទី ១៣/០២/១៩៩៨ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ដើម្បីអនុវត្តសេចក្តីអំពាវនាវ ក្នុងការប្រលងប្រណាំងស្តីពីការឈប់ជក់បារីអោយមានប្រសិទ្ធភាព ក្រសួងអប់រំយុវជន និងកីឡា សំណូមពរអោយបណ្តាមន្ទីរ អង្គភាព គ្រឹះស្ថានសិក្សានានាក្រោមឱវាទក្រសួង យកចិត្តទុកដាក់រៀបចំផ្សព្វផ្សាយអប់រំទប់ស្កាត់ការជក់បារី នៅកន្លែងធ្វើការរួមគ្នា សាលប្រជុំ និងគ្រឹះស្ថានសិក្សា ។

ទន្ទឹមនឹងនេះ បើមន្ទីរ អង្គភាព គ្រឹះស្ថានសិក្សាយល់ថា មិនទាន់អាចបំបាត់ការជក់បារីទាំងស្រុងទេ ស្នើសុំអោយរៀបចំកន្លែងមួយដាច់ដោយឡែក ទុកសំរាប់អ្នកញៀនបារីជក់នៅទីនោះ ជៀសវាងប៉ះពាល់ដល់សុខភាពអ្នកដទៃដែលមិនជក់ ។ ព្រមជាមួយនេះ ក៏ស្នើមន្ទីរ អង្គភាព គ្រឹះស្ថានសិក្សា រៀបចំបិទរូបភាពផ្សព្វផ្សាយ អប់រំសុខភាព ស្តីពីផលប៉ះពាល់ដល់សុខភាពដោយសារការជក់បារី ។

ក្រសួងអប់រំយុវជន និងកីឡាសង្ឃឹមថា អស់លោក លោកស្រី ពិតជានឹងខិតខំយកចិត្តទុកដាក់អនុវត្តអោយបានលទ្ធផលល្អប្រសើរតាមសេចក្តីណែនាំនេះ ។

សូមលោកប្រធានទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

រដ្ឋលេខាធិការ

*សូមជូនភ្ជាប់មកជាមួយនូវ:*

- *សេចក្តីអំពាវនាវរបស់ ក្រសួងអប់រំ យុវជន និងកីឡា លេខ៤៥៥ អយក.ម*
- *សំភារៈអប់រំ សំរាប់បិទផ្សាយ*